# សូមផ្តល់ឱកាសមានសុវត្ថិភាព និងការលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្មេងៗ ក្នុងវិស័យឧស្សាហកម្មទេសចរណ៍

សាររបស់លោកស្រី ថេតចិស មាំងហ្គាហាស ប្រធានទីប្រឹក្សាបច្ចេកទេស គំរោងអនុតំបន់មេគង្គប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រី នៃអង្គការពលកម្មអន្តរជាតិ - ILO

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព

ក្នុងនាមការិយាល័យពលកម្មអន្តរជាតិ ILO និងកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ IPEC ខ្ញុំមានសេចក្តីរីករាយណាស់ដែលមានវត្តមានថ្ងៃនេះ និងចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងការប្រកាសនៃការប្រឹងប្រែងរួមរបស់យើង ដើម្បីធានានូវការអភិវឌ្ឍន៍នាពេលអនាគតនៃឧស្សាហកម្មទេសចរណ៍ ដែលរីកចំរើនរបស់ប្រទេសកម្ពុជា អោយមាននិរន្តភាព និងលើកទឹកចិត្តដល់ពលរដ្ឋគ្រប់ៗរូប ។

ឧស្សាហកម្មទេចរណ៍រនៃប្រទេសកម្ពុជា គឺបានឆ្លងកាត់ការរីកចំរើនម្តងហើយម្តងទៀតនាឆ្នាំថ្មីៗនេះ និងកំពុងតែលេចធ្លោឡើងថា ជាវិស័យមួយក្នុងចំណោមវិស័យទាំងឡាយដែលមានផ្នែកសេដ្ឋកិច្ចរីកចំរើនខ្លាំងបំផុត ។ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិបានកើនឡើងគួរអោយកត់សំគាល់ក្នុងឆ្នាំ ២០០៤ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងចំណូលជាតិ និងបានបង្កើតការងារជូនប្រជាពលរដ្ឋចំនួន ១៨០ ០០០នាក់ ។

ហើយ.....ភាពដ៏ល្បីល្បាញកំពុងតែបានកសាងឡើង ។ ព្រលានយន្តហោះទំនើបទទួលស្វាគមន៍ ភ្ញៀវទេសចរណ៍ដែលមកកាន់ទីក្រុងភ្នំពេញ ។ ភាពដ៏ល្អប្រណិត របស់ប្រាសាទអង្គរវត្ត បានទាក់ទាញភ្ញៀវទេសចរណ៍ពីគ្រប់ប្រទេសក្នុងពិភពលោក និងជាកាពិតណាស់ ការកើនឡើងនូវចំនួនភ្ញៀវទេសចរណ៍ជាតិ កំពុងតែបានទស្សនាប្រទេសរបស់ខ្លួន និងកំពុងតែសប្បាយរីករាយនៅតាមតំបន់ទេសចរណ៍នានា ដូចជាក្រុងព្រះសីហនុជាដើម ។ នេះមានន័យថា មានសណ្ឋាគារច្រើន ភោជនីយ៍ដ្ឋានច្រើន និងមានឳកាសច្រើនសំរាប់សហគ្រិនតូចៗ ដើម្បីស្វែងរកនិងបំពេញការងារចំពោះភាគហ៊ុនរបស់គេ ក្នុងរូបិយបណ្ណ័ទេសចរណ៍ ( រៀល ) ។

ទន្ទឹមនេះអ្វីដែលកត់សំគាល់ជាងនោះគឺ ទេសចរណ៍ជាតិមានចំនួន ៤ដង ច្រើនជាងទេសចរណ៍អន្តរជាតិ ។ នេះបង្ហាញថា ការរីកចំរើនសេដ្ឋកិច្ចក្នុងស្រុក និងវិបុលភាពកំពុងតែផ្តល់ឳកាសនានាច្រើន ចំពោះចលនា និងការធ្វើដំណើរក្នុងប្រទេស ។ អំឡុងពេលរីកចំរើននេះ គឺជាពតិមានល្អចំពោះសេដកិច្ចកម្ពុជា និងបង្កើតការងារថ្មីៗសំរាប់ប្រជាពលរដ្ឋត្រូវការ ។ ជាមួយនេះផងដែរមានការបង្ហាញនៅតាមតំបន់នានា ដែលទេសចរណ៍បាន

ដំណើរការខុសឆ្គង និងជាកន្លែងនោះហើយ ដែលយើងត្រូវការធ្វើសកម្មភាពយ៉ាងឆាប់រហ័ស ដើម្បីបង្ការការពារនូវផលប្រយោជន៍ និងការរួមចំណែកក្នុងផ្នែកដែលកំពុងរីកចំរើននេះ ។

ខ្ញុំមានមតិនៅទីនេះ គឺចង់បញ្ជាក់ពីប្រជាពលរដ្ឋក្មេងៗដែលគ្មានចំណេះដឹងបានស្រូបទាញទៅក្នុងតំបន់ទេសចរណ៍កំពុងតែរីកចំរើន ដើម្បីស្វែងរកការងារធ្វើ ។ តាមពិតនោះ យុវជនវ័យក្មេងអាចរកការងារថ្មីៗក្នុងវិស័យទេសចរណ៍ ក៏ប៉ុន្តែមានភស្តុតាងខ្លះបានបញ្ជាក់ថា មានខ្លះក្នុងចំណោមពួកគេមានបទពិសោធន៍ថា ត្រូវបានគេបង្ខំទៅក្នុងស្ថានភាព រំលោភបំពានផ្សេងៗដូចជា ស្រ្តីរកស៊ីផ្លូវភេទ និងការកេងប្រវ័ញ្ចកំលាំងពលកម្មតាមរយៈការប្រើឧបាយកល ការបោកប្រាស់ និងទំរង់ផ្សេងៗ ទៀតនៃការបង្ខិតបង្ខំ ។

ប៉ុន្តែការដែលឧស្សាហកម្មទេចរណ៍រីកចំរើននេះ គឺមិនមែនជាហេតុផលសំរាប់ធ្វើអោយភ័យខ្លាចនោះទេ។ ការដែលបានគ្រប់គ្រងយ៉ាងត្រឹមត្រូវល្អ វាអាចជាកំលាំងវិជ្ជមានមួយក្នុងការអភិវឌ្ឍន៍ និងសំរាប់រួមចំណែកដល់ផលប្រយោជន៍របស់មនុស្សគ្រប់ៗរូប ។ ក៏ប៉ុន្តែយើងត្រូវចាប់ផ្តើមធ្វើសកម្មភាពឥឡូវនេះ ។

ហេតុផលនេះហើយ បានជាអង្គការ ILO គំរោងអនុតំបន់ទន្លេមេគង្គ ប្រឆាំងការជួញដូរកុមារ និងស្រ្តីបានចូលទៅក្នុងភាពជាដៃគូរនេះជាមួយនិងក្រសួងទេសចរណ៍ ។ យើងចង់ធ្វើផ្នែករបស់យើង ដើម្បីជួយដល់ប្រជាពលរដ្ឋកម្ពុជាក្មេងៗ និងប្រជាពលរដ្ឋក្មេងៗដ៏ទៃទៀត មកពីមហាអនុតំបន់ទន្លេមេគង្គ រកការងារល្អៗបាន និងជៀសវាងការធ្លាក់ចូលទៅក្នុងកណ្តាប់ដៃរបស់ពួកអ្នកចង់រំលោភបំពានលើពួកគេ ។

យើងអាចធ្វើការរបៀបនេះ ដោយមានគាំទ្រការខិតខំប្រឹងប្រែងរបស់ក្រសួង ដើម្បីលើកកំពស់ការយល់ដឹងដល់និយោជក និងកម្មករក្មេងៗ ដែលមានសក្តានុពលនៅក្នុងប្រទេសកម្ពុជា អំពីវិធី ដើម្បីជៀសវាងពីស្ថានភាពងាយស្រួលរងគ្រោះ និងការរំលោភបំពាននានា ។

ជាផ្នែកមួយនៃការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសំរបសំរួល ការសន្យាប្រឆាំងការជួញដូរក្នុងអនុតំបន់របស់ខ្លួន ក្នុងដំណើរការ ការសំរបសំរួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្រ្តីប្រឆាំងការជួញដូរមនុស្ស (COMMIT) អង្គការពលកម្មអន្តរជាតិ ILO គាំទ្រសកម្មភាពផែនការយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល តាមរយៈឧបត្ថម្ភគាំទ្រការអភិវឌ្ឍន៍គោលការណ៍ប្រតិបត្តិ និងសៀវភៅបណ្តុះបណ្តាល ដើម្បីអនុវត្តយុទ្ធនាការសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍របស់រដ្ឋាភិបាល ។

ប៉ុន្តែការគាំទ្ររបស់យើង គឺមានលើសពីការអភិវឌ្ឍន៍ ក្បួនខ្នាតណែនាំនេះ ។ យើងនឹងជួយផ្តល់ការបណ្តុះបណ្តាលតាមមូលដ្ឋានដល់ក្រុមងាយរងគ្រោះក្នុងខេត្តសៀមរាប ក្រុងព្រះសីហានុ និងនៅទីក្រុងភ្នំពេញ ។

យើងកំពុងតែគាំទ្រការងាររបស់រាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ខេត្ត និងក្រុងតាមរយៈក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធានាដល់ប្រជាពលរដ្ឋក្មេងៗ ត្រូវបានយល់ដឹងនៅកន្លែងធ្វើការងារណាដែលអាចកើតឡើងនូវភាពងាយរងគ្រោះខ្លាំងនៃការរំលោភបំពាន ។

ដើម្បីធានាអោយបានកាន់តែប្រសើរឡើងនូវ នៅកន្លែងការងារទេសចរណ៍មានដំណើរការត្រឹមត្រូវ និងនាំមកនូវផលប្រយោជគ្រប់ៗគ្នានោះ យើងនឹងគាំទ្រក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងសកម្មភាពត្រួតពិនិត្យនៅកន្លែងការងារ ។

យើងកំពុងធ្វើការជាមួយអង្គការអន្តរជាតិផងដែរ និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីកសាងសម្ព័ន្ធភាពការងាររឹងមាំក្នុងយុទ្ធនាការនេះ ។

ពីសណ្ឋាគារ និងផ្ទះសំណាក់ ដល់ភោជនីយដ្ឋាន និងកន្លែងកំសាន្តនានា យើងគួរធ្វើការទាំងអស់គ្នា ដើម្បីបង្ហាញពិភពលោកថា កុមារទាំងឡាយអាចត្រូវបានរក្សាក្នុងបរិយាកាសសុវត្ថិភាព និងប្រជាពលរដ្ឋក្មេងៗមានឱកាសជាក់លាក់ទទួលបានការងារសមស្រប ក្នុងបរិយាកាសសុវត្ថិភាព និងបរិយាកាសទេសចរណ៍ដែលបានត្រួតពិនិត្យ ។

ឱកាសនេះមកដល់មិនមែនក្នុងពេលឆាប់ៗនេះទេ យើងដឹងហើយ នៅទូទាំងមហាអនុតំបន់ទន្លេមេគង្គ មួយឆ្នាំៗ ប្រជាពលរដ្ឋក្មេងៗរាប់រយរាប់ពាន់នាក់ថែមទៀត កំពុងតែចូលរួមក្នុងកំលាំងពលកម្ម ។ យើងក៏ដឹងផងដែរថា មានចំនួនតិចតួចណាស់ ពេញចិត្តនិងជីវិតរស់នៅតាមភូមិ ឬអាជីពជាកសិករ ។ និន្នាការចំណាកស្រុកកើនឡើងនេះ គួបផ្សំនិងចលនារីកចំរើនបន្តនៃផ្នែកទេសចរណ៍ ដែលតម្រូវអោយមានការបណ្តុះបណ្តាលបែបនេះ និងការត្រួតពិនិត្យនៅកន្លែងការងារជាលក្ខណៈសំខាន់ ។

ខ្ញុំសូម ប្រសិទ្ធិពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលបានជោគជ័យក្នុងកិច្ចខិតខំប្រឹងប្រែង ។ ក្នុងនាម ILO IPEC និងជំរាប ឯកឧត្តម លោកជំទាវ លោក លោកស្រីថា យើងនឹងបន្តការគាំទ្រ និងជំនួយបច្ចេកទេស ជាបន្តទៅទៀត ។

សូមអរគុណ